ឈ្មោះសហគ្រាសឯកបុគ្គល/ក្រុមហ៊ុនសហកម្មសិទ្ធិ (លេខចុះបញ្ជី) [សម្រាប់ភ្ជាប់គណនីដើម្បីប្រើសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង]

ភ្ជាប់គណនីសម្រាប់ប្រើសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង

Sole Proprietorship/Partnership Name (Registration Number) [For Linking of Accounts for Hong Leong Business Internet/Electronic Banking]

LINKING OF ACCOUNTS FOR HONG LEONG BUSINESS INTERNET/ELECTRONIC BANKING

*ការភ្ជាប់គណនីអាចអនុវត្តបានតែចំពោះសហគ្រាសអាជីវកម្មដែលមានកម្មសិទ្ធិករ/សហកម្មសិទ្ធិករដូចគ្នាតែប៉ុណ្ណោះ*

*Linking of accounts is only applicable for businesses which have exactly the same owner(s)/partners*

# លិខិតអនុញ្ញាត

## LETTER OF AUTHORISATION

ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ, ________________________________ (ឈ្មោះ និងលេខអត្តសញ្ញាណប័ណ្ណ) ជាកម្មសិទ្ធិករ/សហកម្មសិទ្ធិករនៃ ________________________ ("សហគ្រាសអាជីវកម្ម")។

I/We, (name and NID number) being the owner(s) / partner(s) of ("the Business")

ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ សូមបញ្ជាក់ថា ________________________________ដែលជាកម្មសិទ្ធិរបស់ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ ("សហគ្រាសអាជីវកម្មពាក់ព័ន្ធ") បានចុះ ឬ នឹងចុះកិច្ចព្រមព្រៀង ជាមួយធនាគារហុង លីអុង (ខេមបូឌា) ភីអិលស៊ី (តទៅនេះហៅថា "ធនាគារ ហុង លីអុង") លើសេវា និង/ឬផលិតផលដែលហៅថាសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង និងសេវាកម្មផ្សេងៗទៀតដែលអាចត្រូវបន្ថែម ដកចេញ កែប្រែ ឬ ជំនួស (ជារួមហៅថា "សេវា") ដោយធនាគារហុង លីអុង នៅគ្រប់ពេល ឬពីពេលមួយទៅពេលមួយ ដើម្បីឱ្យសហគ្រាសអាជីវកម្មពាក់ព័ន្ធអាចបំពេញសេវាធនាគារបានតាមរយៈប្រព័ន្ធអ៊ីនធឺណិត ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌស្តីពីសេវា ដែលអាចរកបាននៅក្នុងគេហទំព័ររបស់ ធនាគារ ហុង លីអុង (www.hlb.com.kh) ("បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់សេវាធនាគារតាមអ៊ីនធឺណិតសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារ ហុង លីអុង") និងបញ្ញត្តិ និងលក្ខខណ្ឌបន្ថែម កែប្រែ ឬ ជំនួសផ្សេងទៀតដែល ធនាគារ ហុង លីអុង បង្កើតឡើងពីពេលមួយទៅពេលមួយ។

I/We hereby confirm that which is owned by me/us ("The Related Business") has entered or will enter into an agreement with Hong Leong Bank (Cambodia) Plc (HLBCAM) for the services and/or facilities described as Hong Leong business internet/electronic banking and such other services as may be added, withdrawn, varied or replaced (collectively, "the Services") by HLBCAM at any time or from time to time to enable the Related Business to perform banking services through the internet upon the terms and conditions of the Services, which are available on HLBCAM's website at www.hlb.com.kh ("TERMS AND CONDITIONS FOR HONG LEONG BUSINESS INTERNET BANKING") and such other additional, varied or substituted terms and conditions as HLBCAM may stipulate from time to time.

សហគ្រាសអាជីវកម្មបើកគណនី/សេវាពាណិជ្ជកម្មដូចបានរៀបរាប់/ចង្អុលបង្ហាញក្នុងឧបសម្ព័ន្ធ១.០ ជាមួយធនាគារហុង លីអុង ("គណនីអាជីវកម្ម") ដែលត្រូវរួមបញ្ចូលគណនី/សេវាពាណិជ្ជកម្មផ្សេងៗទៀត ដែលអាចត្រូវបានបើកដោយសហគ្រាសអាជីវកម្ម ជាមួយធនាគារ ហុង លីអុង ពីពេលមួយទៅពេលមួយ។

The Business maintains the Account(s)/Trade Services as listed/indicated in Appendix 1.0 with HLBCAM ("the Business Accounts") which expression shall include such other accounts/trade services, which may be maintained by Business with HLBCAM from time to time.

A. **លិខិតអនុញ្ញាតនេះត្រូវបានសម្រេចដូចតទៅ/ It is hereby resolved as follow:**

ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំសូមធ្វើការព្រមព្រៀង និង/ឬអនុញ្ញាតដោយពុំកែប្រែ និងមិនអាចប្រកែកបាន ឱ្យធនាគារ ហុង លីអុង ធ្វើសកម្មភាពដូចខាងក្រោម៖

I/We hereby irrevocably consent and/or authorise HLBCAM as follows

1. អនុញ្ញាតឱ្យសហគ្រាសអាជីវកម្មពាក់ព័ន្ធ អាចចូលប្រើប្រាស់គណនីអាជីវកម្មពីពេលមួយទៅពេលមួយ ទាក់ទងនឹងសេវាដែលផ្តល់ឱ្យដោយ ធនាគារ ហុង លីអុងទៅកាន់សហគ្រាសអាជីវកម្មពាក់ព័ន្ធ។

   To allow the Related Business to have access to the Business Accounts from time to time in relation to the Services provided by HLBCAM to the Related Business;

2. អនុញ្ញាតឱ្យបុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាចឱ្យដោយសហគ្រាសអាជីវកម្មពាក់ព័ន្ធ ចូលប្រើប្រាស់សេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង សម្រាប់ និងក្នុងនាមសហគ្រាសអាជីវកម្មពាក់ព័ន្ធពីពេលមួយទៅពេលមួយ ដើម្បីសាកសួរ និង/ឬធ្វើប្រតិបត្តិការ (សកម្មភាពណាមួយដែលត្រូវធ្វើ) ស្របតាមសេវាសម្រាប់គណនីអាជីវកម្ម។

   To allow the person(s) authorised by the Related Business to access Hong Leong business internet/electronic banking for the Related Business from time to time to enquire and/or transact (whichever is applicable) under the Services for the Business Accounts.

3. "សហគ្រាសអាជីវកម្មយល់ព្រម និងអនុញ្ញាតឱ្យ ធនាគារ ហុង លីអុង ពឹងផ្អែកលើ និងធ្វើសកម្មភាពស្របតាមបញ្ជាណែនាំ ឬការប្រាស្រ័យទាក់ទងនានា ("ការបញ្ជា") ដែលពីពេលមួយទៅពេលមួយ អាច ឬ នឹងអាចធ្វើឡើងដោយ ឬក្នុងនាមសហគ្រាសអាជីវកម្មនិង/ឬសហគ្រាសអាជីវកម្មពាក់ព័ន្ធ ចំពោះបុគ្គលដែលបានទទួលសិទ្ធិប្រើប្រាស់ និងអាចចូលប្រើប្រាស់សេវាបានតាមរយៈសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារ ហុង លីអុង ដោយមិនចាំបាច់មានការសាកសួរ ឬការបញ្ជាក់ពីភាគី ធនាគារ ហុង លីអុង ឡើយ ពាក់ព័ន្ធនឹងសិទ្ធិអំណាច ឬអត្តសញ្ញាណរបស់បុគ្គលដែលបានទទួលសិទ្ធិនោះ ឬ បុគ្គលផ្តល់ការបញ្ជា ឬនឹងអាចផ្តល់ការបញ្ជា ឬចំពោះភាពត្រឹមត្រូវតាមផ្លូវច្បាប់នៃការបញ្ជានោះផងដែរ។ ធនាគារ ហុង លីអុង មានសិទ្ធិចាត់ទុករាល់ការបញ្ជាទាំងនោះមានអានុភាពគតិយុត្តិលើសហគ្រាសអាជីវកម្ម និង/ឬសហគ្រាសអាជីវកម្មពាក់ព័ន្ធ ហើយ ធនាគារ ហុង លីអុង ត្រូវមានសិទ្ធិធ្វើសកម្មភាពទាំងឡាយទាក់ទងនឹង ឬដោយផ្អែកលើការបញ្ជានោះ។ ក្នុងករណីនេះ សហគ្រាសអាជីវកម្ម និង/ឬសហគ្រាសអាជីវកម្មពាក់ព័ន្ធ យល់ព្រមទទួលទទួលខុសត្រូវនូវរាល់ហានិភ័យពាក់ព័ន្ធនឹងការបញ្ជានោះ ព្រមទាំងមិនតវ៉ានឹងសុពលភាព ភាពត្រឹមត្រូវតាមផ្លូវច្បាប់ និងភាពត្រឹមត្រូវនៃការបញ្ជានោះឡើយ។"

   "THAT the Business agrees and authorises HLBCAM to rely upon and act in accordance with any instructions or communication ("Instructions") which may be from time to time be, or purport to be given by or on behalf of the Business and/or the Related Business in respect of the persons authorised to use and to access the Services via Hong Leong business internet/ electronic banking without inquiry or verification on HLBCAM's part as to the authority or identity of the persons so authorised or the person giving or purporting to give the Instructions or as to the authenticity of such Instructions. HLBCAM is entitled to treat all such Instructions as binding upon the Business and/or the Related Business and HLBCAM shall be entitled to take such steps in connection with or in reliance upon such Instructions. In this regard, the Business and the Related Business agree to bear all risks involved in giving the Instructions and will not challenge the validity, authenticity and accuracy of the Instructions."

4. "លិខិតបញ្ជាក់សេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃលិខិតអនុញ្ញាតនេះត្រូវផ្តល់ទៅឱ្យ ធនាគារ ហុង លីអុង ហើយលិខិតអនុញ្ញាតនេះត្រូវមានសុពលភាពរហូតដល់ ធនាគារ ហុង លីអុង ទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ទុយពីនេះពីខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ។"

   "That a certified true copy of this Letter of Authorisation is to be furnished to HLBCAM and this Letter of Authorisation shall remain in force and binding until notice in writing to the contrary is given to HLBCAM by me/us."

ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំយល់ព្រមដោយឥតលក្ខខណ្ឌ និងពុំអាចប្រកែកបានក្នុងការ សងសំណងដល់ ធនាគារ ហុង លីអុង និងបន្តសងសំណងដល់ ធនាគារ ហុង លីអុង ចំពោះរាល់ពាក្យបណ្តឹង ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ការខូចខាត ថ្លៃចំណាយ និងការចំណាយនានា ដែលអាចកើតមានឡើងចំពោះ ធនាគារ ហុង លីអុង ដែលកើតចេញពី ឬជាលទ្ធផលនៃលិខិតអនុញ្ញាតនេះ និង/ឬការធ្វើសកម្មភាពស្របតាមលិខិតអនុញ្ញាតនេះ និង/ឬការបញ្ជា របស់ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំដែលផ្តល់ឱ្យ ធនាគារ ហុង លីអុង។

I/We hereby unconditionally and irrevocably agree to indemnify the HLBCAM and shall keep HLBCAM indemnified against any and all actions, claims demands, liabilities, losses, damages, costs and expenses of whatever nature which the HLBCAM may suffer, incur or sustain arising from or as a result of this Letter of Authorisation and/or adhering to my/our instruction/authorisation herein given to HLBCAM.

លិខិតអនុញ្ញាតនេះត្រូវជំនួសឱ្យរាល់ការ បញ្ជាឬការអនុញ្ញាត ទោះដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលមានពីមុនដែលចេញដោយខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំពាក់ព័ន្ធនឹងសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិក សម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង។

This Letter of Authorisation shall supersede any prior oral or written instruction or authorisation given by me/us in connection with the Hong Leong business internet/ electronic banking.

ធ្វើនៅថ្ងៃទី/ Dated this ______ខែ/ day of__________ ឆ្នាំ ២0/20_____

បានបញ្ជាក់ថាត្រឹមត្រូវ

Certified Correct,

| _____________________________ | _____________________________ |
| --- | --- |
| ឈ្មោះ: | ឈ្មោះ: |
| Name | Name |
| តំណែង: | តំណែង: |
| Designation | Designation |

## ឧបសម្ព័ន្ធ ១.០

Appendix 1.0

| លេខគណនី<br>ACCOUNT NUMBER | ឈ្មោះគណនី<br>ACCOUNT NAME |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |